ព្រះរាជាណាចក្រកម្ពុជា

ជាតិ   សាសនា   ព្រះមហាក្សត្រ

# របាយការណ៍ស្តីពី

# វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់

# ថ្នាក់ក្រុង ស្រុក ខណ្ឌ




ខែ មករា ឆ្នាំ២០១៤

# មាតិកា


| | | ទំព័រ |
|---|---|---|
| I. | សេចក្តីផ្តើម | ១ |
| II. | គោលបំណង | ១ |
| III. | ដំណើរការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ | ២ |
| IV. | លទ្ធផលវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ | ៦ |
| V. | សំណើ/បញ្ហានានាលើកឡើងដោយអ្នកចូលរួម | ១២ |
| VI. | សកម្មភាពអាទិភាពរបស់រដ្ឋបាលក្រុងស្រុកខណ្ឌក្នុងឆ្នាំ២០១៤ | ១៤ |
| VII. | សន្និដ្ឋានលើដំណើរការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ | ១៥ |
| VIII. | អនុសាសន៍កែលម្អសម្រាប់រៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ឆ្នាំបន្ទាប់ | ១៨ |

## I. សេចក្តីផ្តើម

ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌដែលបានបង្កើតឡើងតាមការបោះឆ្នោត គឺជាតំណាងសាធារណៈ ជាអ្នកការពារ និងបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្នុងន័យនេះ ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់អំពីការធ្វើសេចក្តីសម្រេចចិត្តនិងការចាត់ចែងអនុវត្តសេចក្តីសម្រេចចិត្តទាំងនោះក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់កិច្ចអភិវឌ្ឍតាមបែបប្រជាធិបតេយ្យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ជាសាធារណៈ គឺជាឧបករណ៍ដ៏មានសារសំខាន់មួយសម្រាប់ការចូលរួមចំណែកធានាដល់ការជំរុញ និងការលើកកម្ពស់គណនេយ្យភាពរបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌចំពោះប្រជាពលរដ្ឋក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការចាត់ចែងអនុវត្តសេចក្តីសម្រេចចិត្តដែលផ្តល់ផលប៉ះពាល់ដល់ប្រយោជន៍ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ពាក់ព័ន្ធនឹងកិច្ចការដ៏មានសារសំខាន់នេះ អនុក្រឹត្យលេខ២១៥ អនក្រ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌ និងអនុក្រឹត្យលេខ២១៦ អនក្រ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក បានផ្តល់កាតព្វកិច្ចឱ្យក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌក្នុងការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ក្នុងអំឡុងខែមិថុនានៃឆ្នាំនីមួយៗជារៀងរាល់ឆ្នាំ។

របាយការណ៍នេះផ្តោតទៅលើកិច្ចដំណើរការ និងលទ្ធផលបូកសរុប និងសំណើរសំណូមពរពាក់ព័ន្ធនឹងការរៀបចំវេទិកាផ្សព្វផ្សាយ និងការពិគ្រោះយោបល់ជាសាធារណៈរបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌដែលបានអនុវត្តក្នុងឆ្នាំ២០១៣កន្លងមក និងផែនការរៀបចំវេទិកាផ្សព្វផ្សាយ និងការពិគ្រោះយោបល់ជាសាធារណៈរបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌក្នុងឆ្នាំ២០១៤។

## II. គោលបំណង

វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានគោលបំណងដើម្បី៖

- ផ្តល់ព័ត៌មានស្តីពីតួនាទី មុខងារ អាណត្តិរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- ផ្តល់ព័ត៌មានស្តីពីសកម្មភាពអភិវឌ្ឍនានាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- បង្ហាញសមិទ្ធផល និងថវិកាដែលក្រុមប្រឹក្សាសម្រេចបានកន្លងមក និងបញ្ហាប្រឈមនានា

- បង្ហាញអាទិភាពនៃការងារអភិវឌ្ឍន៍ និងថវិការបស់ក្រុមប្រឹក្សាសម្រាប់ឆ្នាំខាងមុខ
- ផ្ដល់ឱកាសដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធក្នុងការលើកឡើងនូវសំណើ សំណូមពរ និង បញ្ចេញមតិយោបល់នានា ពាក់ព័ន្ធការងារគ្រប់គ្រង និងកិច្ចអភិវឌ្ឍមូលដ្ឋាន
- ផ្ដល់ឱកាសដល់ក្រុមប្រឹក្សាទទួលយកអនុសាសន៍សំណើនិងសំណូមពររបស់ប្រជាពលរដ្ឋ ដើម្បីពិភាក្សា និងឆ្លើយតប។

## III. **ដំណើរការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់**

វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ គឺជាព្រឹត្តិការណ៍ប្រចាំឆ្នាំដ៏សំខាន់របស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាមុខងារត្រូវបំពេញក្នុងនាមជាអាជ្ញាធរមូលដ្ឋានដែលជាប់ឆ្នោត ដូចដែលមានចែងនៅក្នុងអនុក្រឹត្យលេខ២១៥អនក្រ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌ និងអនុក្រឹត្យលេខ២១៦ អនក្រ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក។ ហេតុនេះតម្រូវឱ្យក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីទាំងអស់ចូលរួមសហការ និងគាំទ្រដល់ដំណើរការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់។

ដោយមានឯកសារបច្ចេកទេសស្ដីពីវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សានិងយន្តការសម្របសម្រួលប្រឹក្សាយោបល់ដែលផ្ដល់លេខាធិការដ្ឋាន គ.ជ.អ.ប ជាជំនួយស្មារតីវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ ត្រូវដំណើរការរៀបចំមានដូចខាងក្រោម៖

### **១. ការត្រៀមរៀបចំវេទិកា**

នៅក្នុងដំណើរការត្រៀមរៀបចំវេទិកាដើម្បីឱ្យប្រព្រឹត្តទៅបានដោយរលូន និងមានប្រសិទ្ធភាព ចាំបាច់ត្រូវមានត្រៀមរៀបចំវេទិកាឲបានគ្រប់ជ្រុងជ្រោយ។ ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវពិចារណាអំពីការត្រៀមរៀបចំវេទិការបស់ខ្លួន។ សកម្មភាពនានាដែលត្រូវធ្វើរួមមាន ៖

**១.១. ប្រធានក្រុមប្រឹក្សា** អញ្ជើញអភិបាល នាយករដ្ឋបាល និងមេឃុំ ឬចៅសង្កាត់ពាក់ព័ន្ធនានាចូលរួមប្រជុំ ដើម្បីរួមគ្នាពិចារណាលើការត្រៀមរៀបចំវេទិការបស់ក្រុមប្រឹក្សា ជាពិសេសត្រូវមានការឯកភាពគ្នាលើបញ្ហាផ្សេងៗ ដូចជារបាយការណ៍នានា កាលបរិច្ឆេទ ពេលវេលា ទីកន្លែង អ្នកធ្វើបទបង្ហាញ និងប្រធានបទបន្ថែមមួយចំនួន។ ក្រៅពីនេះ នាយករដ្ឋបាល និងមន្ត្រីពាក់ព័ន្ធបានប្រជុំជាមួយអង្គការសង្គមស៊ីវិល ផ្នែកឯកជន ដើម្បីកៀរគរ ការគាំទ្រផ្សេងៗទាំងសម្ភារៈ និងថវិកា។ បញ្ហាសំខាន់ៗសម្រាប់ដាក់ចូលក្នុងសេចក្ដីព្រាងរបៀបវារៈត្រូវលើកយកមកធ្វើការពិចារណារួមមាន ៖

- បញ្ហានានាដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ដែលជាការព្រួយបារម្ភរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន ដូចជា៖ ស្ថានភាពសុខមាលភាព សុខភាពបន្តពូជ ស្ថានភាពសិក្សាអប់រំ ការទទួលបានទឹកស្អាត បញ្ហាក្មេងទំនើង អំពើហឹង្សាក្នុងគ្រួសារ បទល្មើសផ្សេងៗ អសន្តិសុខ និងចំណាកស្រុកគ្មានសុវត្ថិភាព។ល។
- សកម្មភាពសំខាន់ៗដែលក្រុមប្រឹក្សា គណៈអភិបាល មន្ទីរ ឬការិយាល័យ និងអង្គភាពជំនាញបានអនុវត្តក្នុងរយៈពេលកន្លងមក ព្រមទាំងលទ្ធផលដែលសម្រេចបាន។

**១.២. អភិបាល នាយករដ្ឋបាល និងមន្ត្រីពាក់ព័ន្ធ** រៀបចំសេចក្តីព្រាងរបៀបវារៈ ឯកសារពាក់ព័ន្ធសម្រាប់វេទិកា ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សាពិនិត្យកែសម្រួល ឬសុំការឯកភាពលើឯកសារទាំងនោះ។ សេចក្តីព្រាងឯកសារទាំងនោះអាចរួមមាន សមិទ្ធផលនានាដែលសម្រេចបានប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ស្ថានភាពថវិកា (ចំណូល ចំណាយ) សុន្ទរកថារបស់ប្រធានក្រុមប្រឹក្សា និងអនុសាសន៍ស្តីពីសកម្មភាពអាទិភាពសម្រាប់ឆ្នាំខាងមុខ ដែលស្នើឡើងដោយក្រុមប្រឹក្សានិងអភិបាល។ សេចក្តីព្រាងឯកសារទាំងនេះ គឺត្រូវដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សា ដើម្បីពិភាក្សា កែសម្រួល និងឯកភាព។

**១.៣. ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ** ត្រូវសម្របសម្រួលវេទិកានេះ ដោយមានការជួយគាំទ្រពីគណៈអភិបាល នាយករដ្ឋបាល និងមន្ត្រីពាក់ព័ន្ធ ព្រមទាំងពីមន្ត្រីសម្របសម្រួល និងប្រឹក្សាយោបល់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុកខណ្ឌ និងទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ជាទូទៅវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ បានដំណើរការដូចខាងក្រោម៖

- មតិស្វាគមន៍ និងបើកវេទិកា
- បង្ហាញរបៀបវារៈ
- បង្ហាញបទបញ្ជាផ្ទៃក្នុង (ហាមរិះគន់បុគ្គលិក, មិនលើកឡើងបញ្ហានយោបាយ....)
- ការណែនាំខ្លួនរបស់សមាជិកក្រុមប្រឹក្សា និងគណៈអភិបាលដែលចូលរួម
- ការបង្ហាញតួនាទី ភារកិច្ច សិទ្ធិអំណាចរបស់ក្រុមប្រឹក្សា និងគណៈអភិបាល
- ការបង្ហាញសមិទ្ធផល ថវិកាប្រចាំឆ្នាំ និងបញ្ហាប្រឈមក្នុងពេលកន្លងមក និងផែនការសកម្មភាពនាឆ្នាំខាងមុខ
- កិច្ចពិភាក្សាលើប្រធានបទជាក់លាក់
- វេទិកា សំណួរ ចម្លើយ រវាងប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល ជាមួយអាជ្ញាធរ សមត្ថកិច្ចពាក់ព័ន្ធ។

**២. ថវិកាចំណាយសម្រាប់រៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់**

ជាទូទៅថវិកាសម្រាប់រៀបចំវេទិកាត្រូវចំណាយលើ៖

- រៀបចំទីកន្លែង (ជួលរោង កៅអី មេក្រូ )
- ថតចម្លងឯកសារផ្សេងៗ និងក្រដាសផ្ទាំងធំ ហ្វឺត
- អាហារសម្រន់ និងទឹក។

ដោយសារថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ពុំមានខ្ទង់ថវិកាដែលបង្ហាញពីការចំណាយសម្រាប់វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ ហេតុនេះ រដ្ឋបាលក្រុង ស្រុក មានការលំបាកក្នុងការលៃលកប្រើប្រាស់ថវិកា និងការទូទាត់ ដោយសារ អភិបាលស្រុកលើកឡើងថាពុំមានក្នុងខ្ទង់ថវិកាប្រចាំឆ្នាំ។ ប៉ុន្តែដោយសារមានការជំរុញពីក្រុមប្រឹក្សា និងការផ្តល់យោបល់របស់មន្ត្រីសម្របសម្រួលក្រុមប្រឹក្សា អភិបាលក្រុង ស្រុកបានលៃលកប្រើប្រាស់ថវិកាក្នុងខ្ទង់ចំណាយប្រតិបត្តិការទូទៅ សម្រាប់ចំណាយលើការរៀបចំវេទិកានេះ។ ចំណែករដ្ឋបាលខណ្ឌនៅរាជធានីភ្នំពេញពុំមានបញ្ហាការខ្វះខាតថវិកាទេ។

ចំនួនថវិកាដែលត្រូវចំណាយសម្រាប់វេទិកានីមួយៗមានការប្រែប្រួលតាមក្រុង ស្រុក ខណ្ឌនីមួយៗ ក្នុងចន្លោះពីចំនួន **៤០០.០០០រៀល - ២.២០០.០០០រៀល**ក្នុងវេទិកានីមួយៗ អាស្រ័យលើចំនួនអ្នកចូលរួម និងប្រភេទនៃការចំណាយ។ ក្រៅពីថវិការបស់រដ្ឋបាលក្រុង ស្រុកផ្ទាល់ ការចំណាយក្នុងការរៀបចំវេទិការបស់ក្រុមប្រឹក្សាក៏មានការរួមចំណែកពីបណ្តាអង្គការសង្គមស៊ីវិល និងវិស័យឯកជនដែលកំពុងបំពេញការងារក្នុងដែនសមត្ថកិច្ចក្រុង ស្រុក តាមរយៈការសម្របសម្រួល និងកៀរគររបស់រដ្ឋបាលក្រុង ស្រុក។

ជាទូទៅ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នៅតាមក្រុង ស្រុក ខណ្ឌ នីមួយៗត្រូវបានរៀបចំរយៈពេលមួយព្រឹក។ ប៉ុន្តែមានក្រុង ស្រុក មួយចំនួនតូច បានរៀបចំវេទិកានេះមួយថ្ងៃពេញ ដោយមានការផ្តល់អាហារថ្ងៃត្រង់ដល់អ្នកចូលរួម ដែលទទួលការឧបត្ថម្ភដោយអង្គការសង្គមស៊ីវិលដែលកំពុងបំពេញការងារក្នុងដែនសមត្ថកិច្ចក្រុង ស្រុក។

### ៣. ការកៀរគរធនធានសម្រាប់រៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់

ការកៀរគរ និងស្វែងរកថវិកាបន្ថែមសម្រាប់គាំទ្រវេទិកាក្រុមប្រឹក្សាក្រុង ស្រុកទទួលបានការគាំទ្រមួយផ្នែកធំពីអង្គការដៃគូដែលកំពុងបំពេញការងារក្នុងក្រុង ស្រុកនីមួយៗ និងមួយផ្នែកពីស្ថាប័នឯកជន និងសប្បុរសជនមួយចំនួនផងដែរ។ ក្នុងការកៀរគរថវិកានេះ ប្រធានក្រុមប្រឹក្សាក្រុង ស្រុក និងអភិបាលក្រុង ស្រុកបានចេញលិខិតអំពាវនាវតាមបណ្តាអង្គការមិនមែនរដ្ឋាភិបាល ឯកជន និងសប្បុរសជន នានាដែលមានការគាំទ្រលើសកម្មភាពវេទិកានេះ។ ការរួមចំណែករបស់អង្គការ និងស្ថាប័នឯកជនទាំងនោះមានទាំងថវិកា និងសម្ភារៈ(ដូចជាជួលរោង កៅអី ទឹក ឬអាហារថ្ងៃត្រង់ជាដើម)។ ក្រោយចប់វេទិការដ្ឋបាលក្រុង ស្រុកបានចេញលិខិតថ្លែងអំណរគុណជូនចំពោះអង្គការសង្គមស៊ីវិល និងសប្បុរសជនដែលបានចូលរួមគាំទ្រ។

**៤. បញ្ហាជួបប្រទះក្នុងការត្រៀមរៀបចំវេទិកា**

ឆ្នាំ២០១៣ គឺជាឆ្នាំដំបូងដែលក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ បានរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ខ្លួនក្នុងអាណត្តិស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានាដែលបានដាក់ឱ្យអនុវត្ត។ ហេតុនេះ មានបញ្ហាមួយចំនួនដែលក្រុមប្រឹក្សាបានជួបប្រទះ ដូចជា៖

- រដ្ឋបាលក្រុង ស្រុក មួយចំនួនពុំបានគ្រោងថវិកាប្រចាំឆ្នាំ ហើយនៅក្នុងផែនការថវិកាប្រចាំឆ្នាំក៏ពុំមានខ្ទង់ថវិកា។ អាស្រ័យហេតុនេះ ក្រុង ស្រុកពុំមានថវិកាសម្រាប់រៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុង ស្រុក
- គណៈអភិបាលក្រុង ស្រុកមួយចំនួនបានយល់ថាការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សា ក្រុង ស្រុកជាកិច្ចការរបស់ក្រុមប្រឹក្សាក្រុង ស្រុក និងមន្ត្រីសម្របសម្រួលក្រុមប្រឹក្សាស្រុក ហេតុនេះ គណៈអភិបាលក្រុង ស្រុកនោះ មិនសូវសហការ និងចូលរួមរៀបចំ
- រដ្ឋបាលក្រុង ស្រុក មួយចំនួននៅពុំទាន់យល់ច្បាស់ថាការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ គឺជាមុខងារជាកាតព្វកិច្ចដែលក្រុមប្រឹក្សាជាប់ឆ្នោត ត្រូវអនុវត្ត ដើម្បីផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋ ព្រមទាំងទទួលយកនូវសំណូមពរ តម្រូវការនានាពីប្រជាពលរដ្ឋមកវិញ សម្រាប់ពិចារណាចាត់វិធានការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវានានា និងការអភិបាលកិច្ចមូលដ្ឋាន
- ការិយាល័យជំនាញជុំវិញក្រុង ស្រុក ខណ្ឌមួយចំនួននៅពុំទាន់បានសហការពេញលេញ ក្នុងការចូលរួមឆ្លើយតបចំពោះបញ្ហា ចម្ងល់នានាដែលលើកឡើងដោយប្រជាពលរដ្ឋ
- ក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីរដ្ឋបាលក្រុង ស្រុកមានកិច្ចការរវល់ច្រើន
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ ភាគច្រើន បានប្រារព្ធវេទិកាតែ១កន្លែងក្នុង១ក្រុង ស្រុក ហេតុនេះ ប្រជាពលរដ្ឋនៅតាមភូមិឆ្ងាយៗមិនអាចចូលរួមបាន ដោយសាររដ្ឋបាលក្រុង ស្រុក ខណ្ឌ ពុំមានថវិកាសម្រាប់ការឧបត្ថម្ភការធ្វើដំណើរ ឬអាហារ
- រដ្ឋបាលក្រុង ស្រុក មួយចំនួន បានប្រារព្ធវេទិកានៅក្នុងបរិវេណសាលាក្រុង ស្រុក ដោយសារពុំមានថវិកាសម្រាប់ជួលរោង ហេតុនេះប្រជាពលរដ្ឋចូលរួមមិនបានទូលំទូលាយ
- រដ្ឋបាលក្រុង ស្រុក មួយមានភាពស្ទាក់ស្ទើរក្នុងការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ ដោយមានការព្រួយបារម្ភខ្លាចអ្នកចូលរួមលើកឡើងនូវបញ្ហារសើបផ្នែកនយោបាយ
- ពេលវេលាវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់កៀកនឹងពេលវេលានៃការបោះឆ្នោតសភាជាតិអាណត្តិទី៥ ហេតុនេះក្រុង ស្រុក មួយចំនួនស្ទាក់ស្ទើរ និងព្រួយបារម្ភក្នុងការរៀបចំវេទិកា។

## IV. លទ្ធផលវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់

### ១. សមាសភាពអ្នកចូលរួម

វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ថ្នាក់ក្រុង ស្រុក ខណ្ឌ មានចូលរួមពីៈ

- សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- គណៈអភិបាលក្រុង ស្រុក ខណ្ឌ
- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ សមាជិកភូមិ
- ប្រជាពលរដ្ឋ
- ក្រុមប្រជាពលរដ្ឋ (សហគមន៍នេសាទ សហគមន៍ព្រៃឈើ ក្រុមយុវជនស្ម័គ្រចិត្ត)
- តំណាងការិយាល័យជំនាញជុំវិញក្រុង ស្រុក ខណ្ឌ
- កងកម្លាំងប្រដាប់អាវុធថ្នាក់ក្រុង ស្រុក ខណ្ឌ (នគរបាលថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់អាវុធហត្ថ និងយោធា)
- អង្គការសង្គមស៊ីវិលនានា។




*សមាសភាពចូលរួមវេទិការួមមានប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល សមត្ថកិច្ចប្រដាប់អាវុធ*

វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ថ្នាក់ក្រុង ស្រុក ខណ្ឌ ជាវេទិកាសាធារណៈដែលបើកទូលាយ សម្រាប់ការចូលរួមពីអ្នកពាក់ព័ន្ធគ្រប់មជ្ឈដ្ឋានក្នុងមូលដ្ឋានរបស់ក្រុង ស្រុក ខណ្ឌ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ជារួមសមាសភាពខាងលើដែលចូលរួមក្នុងវេទិកាត្រូវបានអញ្ជើញដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ចំណែក ប្រជាពលរដ្ឋត្រូវបានអញ្ជើញមកពីភូមិនានាដែលនៅជិតកន្លែងប្រារព្ធវេទិកា ឬអាច

ចូលរួមដោយសេរី តាមការចាប់អារម្មណ៍របស់ពួកគាត់ ដោយពុំចាំបាច់មានការអញ្ជើញ។ ចំនួនអ្នកចូលរួមក្នុងវេទិកានីមួយៗ ចន្លោះពី៥០នាក់-៣០០នាក់។

ចំនួនអ្នកចូលរួមក្នុងវេទិកាតាមក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវបានសរុបក្នុងរាជធានី និងខេត្តនីមួយៗដូចមានបង្ហាញនៅក្នុងតារាងខាងក្រោម។

## ២. ចំនួនវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់តាមក្រុង ស្រុក ខណ្ឌនីមួយៗ

យោងមាត្រា៦៦នៃអនុក្រឹត្យលេខ២១៥ ក្រុមប្រឹក្សាខណ្ឌនីមួយៗ ត្រូវរៀបចំឱ្យមានវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នៅតាមសង្កាត់នានាក្នុងខណ្ឌរបស់ខ្លួន។ ម្យ៉ាងទៀតមាត្រា៦៥ និងមាត្រា១២១នៃអនុក្រឹត្យលេខ២១៦ ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក នីមួយៗត្រូវរៀបចំឱ្យមានវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នៅតាមឃុំ សង្កាត់នានាក្នុងក្រុង ស្រុករបស់ខ្លួន។ តាមស្ថានភាពជាក់ស្តែង ចំនួនវេទិកាក្នុងក្រុង ស្រុក ខណ្ឌនីមួយៗ គឺអាស្រ័យលើការសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាល ដោយផ្អែកលើថវិកា ពេលវេលា ភាពមមាញឹករបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ។ ជាទូទៅក្រុង ស្រុក ខណ្ឌភាគច្រើនបាន រៀបចំវេទិកាតែមួយកន្លែងក្នុងក្រុង ស្រុក ខណ្ឌនីមួយៗ ដោយសារមូលហេតុផ្សេងៗ។ ប៉ុន្តែក៏មានក្រុង ស្រុក មួយចំនួនបានរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នៅគ្រប់ឃុំ។

<u>**ឧទាហរណ៍៖**</u> ខេត្តពោធិសាត់នៅក្នុងស្រុកបាកាន មាន១០ឃុំ ស្រុកភ្នំក្រវាញមាន៦ឃុំ និងស្រុកវាលវែងមាន៥ឃុំ គឺស្រុកទាំងបីបានរៀបចំវេទិកានៅគ្រប់ឃុំ ទាំងអស់។

**ចំនួនវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ និងចំនួនអ្នកចូលរួមក្នុងវេទិកា**
**រៀបចំដោយក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ នៅតាមរាជធានី ខេត្ត នីមួយៗ ក្នុងឆ្នាំ២០១៣**

| ល.រ | រាជធានីខេត្ត | ចំនួនក្រុង ស្រុក ខណ្ឌ | ចំនួនវេទិកា | ចំនួនអ្នកចូលរួម | | |
|---|---|---|---|---|---|---|
| | | | | មន្ត្រីរាជការ | ប្រជាពលរដ្ឋ | សរុប |
| ១ | បន្ទាយមានជ័យ | ៩ | ៩ | ២៥២ | ៤០៥ | ៦៥៧ |
| ២ | បាត់ដំបង | ១៤ | ១៤ | ៨៤៦ | ១៦១៩ | ២៤៦៥ |
| ៣ | កំពង់ចាម | ១៧ | ១៨ | ១០៦៩ | ១៦០២ | ២៦៧១ |
| ៤ | កំពង់ឆ្នាំង | ៨ | ៨ | ៣៩៨ | ៦១៦ | ១០១៤ |
| ៥ | កំពង់ស្ពឺ | ៨ | ៨ | ៥០៩ | ៥៧១ | ១០៨០ |
| ៦ | កំពង់ធំ | ៨ | ៨ | ៩៩២ | ២៦៨៨ | ៣៦៨០ |
| ៧ | កំពត | ៨ | ៨ | ៣៩៥ | ៧៧០ | ១១៦៥ |

| ល.រ | រាជធានីខេត្ត | ចំនួនក្រុង ស្រុក ខណ្ឌ | ចំនួនវេទិកា | ចំនួនអ្នកចូលរួម | | |
|---|---|---|---|---|---|---|
| | | | | មន្រ្តីរាជការ | ប្រជាពលរដ្ឋ | សរុប |
| ៨ | កណ្តាល | ១១ | ១៤ | ៧០៦ | ២២៤៦ | ២៩៥២ |
| ៩ | កោះកុង | ៧ | ៩ | ៥៧០ | ៦១០ | ១១៨០ |
| ១០ | ក្រចេះ | ៦ | ៦ | ៣១៨ | ៧៧៧ | ១០៩៥ |
| ១១ | មណ្ឌលគិរី | ៥ | ៤ | ២២៨ | ៤៣៨ | ៦៦៦ |
| ១២ | ភ្នំពេញ | ៩ | ១១ | ១២៨៨ | ២៣៨១ | ៣៦៦៩ |
| ១៣ | ព្រះវិហារ | ៨ | ២០ | ៩០១ | ១៥១២ | ៣៤១៣ |
| ១៤ | ព្រៃវែង | ១៣ | ២០ | ១២៤៦ | ១៤៩៣ | ២៧៣៩ |
| ១៥ | ពោធិសាត់ | ៦ | ២៩ | ១០៤ | ២៣៧៥ | ២៤៧៩ |
| ១៦ | រតនគិរី | ៩ | ៩ | ៣០៣ | ១១៤៥ | ១៤៤៨ |
| ១៧ | សៀមរាប | ១២ | ២១ | ១៤៩២ | ៤៩៨២ | ៦៤៧៤ |
| ១៨ | ព្រះសីហនុ | ៤ | ៣ | ១០៨ | ៤៧០ | ៥៧៨ |
| ១៩ | ស្ទឹងត្រែង | ៥ | ៦ | ១៧៧ | ៥៨២ | ៧៥៩ |
| ២០ | ស្វាយរៀង | ៨ | ២៦ | ៧២៤ | ១៨១១ | ២៥៣៥ |
| ២១ | តាកែវ | ១០ | ១០ | ៨៥៤ | ៧៩៥ | ១២៤៩ |
| ២២ | ឧត្តរមានជ័យ | ៥ | ៥ | ២២៩ | ៤៤២ | ៦៧១ |
| ២៣ | កែប | ២ | ២ | ៧៩ | ១៣៧ | ២១៦ |
| ២៤ | ប៉ៃលិន | ២ | ២ | ៤០០ | ៣៣ | ៤៣៣ |
| | **សរុប** | **១៩៤** | **២៧០** | **១៤.១៨៨** | **៣០.៥០០** | **៤៤.៦៨៨** |

<u>**សំគាល់៖**</u> ដើម្បីងាយស្រួលយល់ក្នុងរបាយការណ៍នេះពាក្យ៖

(១) **មន្រ្តីរាជការ**៖ សំដៅលើសមាជិក តំណាងមកពីស្ថាប័ន អង្គភាពរបស់រដ្ឋ ដូចជាក្រុមប្រឹក្សា គណៈអភិបាលមន្រ្តីរាជការតាមមន្ទីរ ការិយាល័យជំនាញ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ និងសមាជិកភូមិ។

(២) **ប្រជាពលរដ្ឋ**៖ សំដៅលើប្រជាពលរដ្ឋ អាជីវករ និងសមាជិក តំណាងអង្គការសង្គមស៊ីវិល។

## ៣. មេរៀន និងបទពិសោធន៍ទទួលបានពីដំណើរការវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់

ឆ្លងតាមការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ក្រុមប្រឹក្សា រដ្ឋបាលក្រុង ស្រុក ខណ្ឌ ទទួលបាននូវមេរៀន បទពិសោធន៍ជាច្រើនទាំងចំនុចល្អៗ និងមេរៀនសម្រាប់កែលម្អក្នុងការរៀបចំវេទិកាបន្តបន្ទាប់ ខាងមុខទៀត៖

### ៣.១. មេរៀន និងបទពិសោធន៍ល្អៗនៃការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់

ទោះបីការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាជាការរៀបចំ លើកដំបូងក៏ដោយ ប៉ុន្តែវេទិកានេះ បានផ្តល់នូវមេរៀន និងបទពិសោធន៍ល្អៗដូចខាងក្រោម៖

- វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ ធ្វើឱ្យក្រុមប្រឹក្សា ស្ថាប័ន អង្គភាពរដ្ឋ ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា កាន់តែមានភាពជិតស្និទ និងសហការគ្នាកាន់តែល្អ ដោយបានយល់ដឹងពីតួនាទីរបស់ក្រុមប្រឹក្សា និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ ដែលនឹងពង្រឹងបាននូវប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន
- ក្រុមប្រឹក្សាបានដឹងពីបញ្ហាជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន តាមរយៈសំណូមពរ ឬការលើកយោបល់ផ្ទាល់ពីប្រជាពលរដ្ឋ ដែលផ្តល់លទ្ធភាពដល់រដ្ឋបាលក្រុង ស្រុកខណ្ឌ ដើម្បីដាក់បញ្ចូលបញ្ហាទាំងនេះទៅក្នុងផែនការសកម្មភាពរបស់រដ្ឋបាលក្រុង ស្រុក និងដើម្បីពង្រឹងការអនុវត្តតួនាទីរបស់ខ្លួន
- គណៈអភិបាលក្រុងស្រុក ខណ្ឌភាគច្រើន មានភាពសកម្មក្នុងការទទួលខុសត្រូវលើការរៀបចំវេទិកាទាំងមូល បានលៃលករកថវិកាសម្រាប់រៀបចំវេទិកា ព្រមទាំងបានចូលរួមឆ្លើយសំណួរពីប្រជាពលរដ្ឋនិងអ្នកចូលរួម
- ការិយាល័យមួយចំនួនជុំវិញក្រុងស្រុកខណ្ឌមានការទទួលខុសត្រូវនិងបានត្រៀមខ្លួនក្នុងការចូលរួមឆ្លើយសំណួរនិងស្រាយបំភ្លឺបានល្អ និងបានបង្ហាញឆន្ទៈកែប្រែចំណុចខ្វះខាតក្នុងការអនុវត្តការងារនាពេលខាងមុខទៀត
- ប្រជាពលរដ្ឋបានដឹងពីសមិទ្ធិផល ដែលរដ្ឋបាលក្រុង ស្រុកខណ្ឌសម្រេចបានក្នុងឆ្នាំកន្លងមក និងបានដឹងអំពីសកម្មភាពអាទិភាព និងថវិការបស់រដ្ឋបាលក្រុងស្រុកនាឆ្នាំបន្ទាប់
- ប្រជាពលរដ្ឋសង្គមស៊ីវិល និងមន្ត្រីរាជការក្នុងក្រុង ស្រុក ខណ្ឌ នីមួយៗមានការអបអរសាទរ និងពេញចិត្តចំពោះ ការរៀបចំវេទិកានេះហើយសូមឱ្យមានជាញឹកញាប់ និងជារៀងរាល់ឆ្នាំ ដើម្បីផ្តល់ឱកាសដល់ពួកគាត់ដើម្បីលើកឡើងនូវបញ្ហាផ្សេងៗ ដាក់ជូនក្រុមប្រឹក្សាដោះស្រាយ
- អង្គការសង្គមស៊ីវិញមានការសាទរ និងបានចូលរួមគាំទ្រដល់ការរៀបចំវេទិកា ទាំងថវិកា និងសម្ភារៈផ្សេងៗព្រមទាំងបានផ្សព្វផ្សាយពីសកម្មភាពនានារបស់ខ្លួនឱ្យរដ្ឋបាលក្រុងស្រុកខណ្ឌនីមួយៗបានដឹង

- វេទិកានេះបានលើកកម្ពស់បន្ថែមទៀតនូវតម្លាភាព និងគណនេយ្យភាពរបស់មន្ត្រីរាជការខ្លះនៅតាមក្រុង ស្រុក ខណ្ឌដោយសារក្រុង ស្រុក ខណ្ឌខ្លះបានលើកពីចំណុចអសកម្មរបស់មន្ត្រី
ខ្លួននិងការខ្វះចន្លោះក្នុងការពង្រឹងការអនុវត្តច្បាប់ចំពោះមន្ត្រីនានានៅថ្នាក់ក្រោមជាតិ
- វេទិកានេះក៏បានផ្ដល់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ មានឱកាសជម្រាបដល់ប្រជាពលរដ្ឋនិងសូមឱ្យមានការសហការពីប្រជាពលរដ្ឋ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដើម្បីកែលម្អនៅឆ្នាំក្រោយ និងមានការដាក់ពិន័យចំពោះមន្ត្រីខិលខូចមួយចំនួន
- គណៈអភិបាលបានខិតខំរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនទោះបីពុំទាន់បានគ្រប់ជ្រុងជ្រោយក៏ដោយ ប៉ុន្តែបានផ្ដល់ជាព័ត៌មានសម្រាប់ប្រជាពលរដ្ឋ និងអ្នកចូលរួមបានដឹងពីថវិកាក្រុង ស្រុកមានចំនួនប៉ុន្មានក្នុង១ឆ្នាំ ព្រមទាំងបានដឹងតើថវិកាទាំងនេះបានចំណាយលើអ្វីខ្លះ
- ផ្ដល់ឱកាសដល់ក្រុមប្រឹក្សាក្នុងការពន្យល់ បកស្រាយ ចំពោះបញ្ហា តម្រូវការនានាដែលបានលើកឡើងដោយប្រជាពលរដ្ឋ
- ក្រុមប្រឹក្សា គណៈអភិបាល មានឱកាសក្នុងការផ្សព្វផ្សាយពីតួនាទី និងភារកិច្ចដល់អ្នកពាក់ព័ន្ធ។



*កម្មវិធីសំណួរ ចម្លើយ រវាងប្រជាពលរដ្ឋ និងក្រុមប្រឹក្សា (ស្រុកស្នួល ខេត្តក្រចេះ)*

## ៣.២. មេរៀន និងបទពិសោធន៍ដែលត្រូវកែលម្អបន្ថែមសម្រាប់វេទិកាលើកក្រោយ

- អភិបាល និងគណៈអភិបាលក្រុងស្រុកមួយចំនួននៅមិនទាន់យល់ពីគោលបំណង និងខ្លឹមសារនៃការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាដោយគិតថាវេទិកា គឺជាសម្រាប់តែអង្គការក្រៅរដ្ឋាភិបាល ឬសង្គមស៊ីវិល។ ក្រៅពីនេះមន្ត្រីខ្លះយល់ថា

វេទិកាបែបនេះ នឹងផ្តល់ឱកាសឱ្យសង្គមស៊ីវិលឬប្រជាពលរដ្ឋ ធ្វើការរិះគន់ស្ថាប័ន អង្គភាពរដ្ឋទៅវិញ

- ការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីការប្រារព្ធវេទិកាមិនទាន់បានទូលំទូលាយធ្វើឱ្យការចូលរួមរបស់ប្រជាពលរដ្ឋនៅមានកម្រិត (តាមក្រុង ស្រុក មួយចំនួន)
- ប្រជាពលរដ្ឋភាគច្រើនលើកសំណូមពរច្រើនដែលពាក់ព័ន្ធការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងមូលដ្ឋាន តែមិនសូវបានលើកពីកង្វល់ជុំវិញការផ្តល់សេវាសាធារណៈនានា ឬការអនុវត្តនៃតួនាទីរបស់ក្រុមប្រឹក្សា និងគណៈអភិបាល
- ថវិការៀបចំវេទិកាមានតិចនាំឱ្យការថតចម្លងឯកសារ និងការរៀបចំទូទៅមិនសូវបានល្អ និងមិនបានគ្រប់គ្រាន់
- តំណាងអង្គភាព ស្ថាប័ន និងការិយាល័យជំនាញពាក់ព័ន្ធពុំបានចូលរួមតាមការអញ្ជើញរបស់រដ្ឋបាលក្រុង ស្រុក ដែលជាហេតុធ្វើឱ្យសំណួរ បញ្ហា និងសំណូមពររបស់ប្រជាពលរដ្ឋមួយចំនួនពុំត្រូវបានពន្យល់ បកស្រាយបំភ្លឺក្នុងអំឡុងពេលធ្វើវេទិកា
- រាល់សំណើសំណូមពររបស់ប្រជាពលរដ្ឋមិនបានដាក់បញ្ចូលទៅក្នុងផែនការអាទិភាពឆ្នាំបន្ទាប់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌដើម្បីដោះស្រាយតាមការលើកឡើងរបស់ប្រជាពលរដ្ឋ
- ក្រុង ស្រុក មួយចំនួន រៀបចំវេទិកាមិនបានគ្រប់ឃុំ សង្កាត់ដោយភាគច្រើនធ្វើបានតែមួយឃុំ ឬមួយសង្កាត់ ក្នុងមួយក្រុងស្រុកនីមួយៗ។ចំណែកខណ្ឌនីមួយៗក្នុងរាជធានីភ្នំពេញ រៀបចំវេទិកាបានតែមួយលើក
- ក្រុង ស្រុក ខណ្ឌ ស្ទើរទាំងអស់មិនមានបិទផ្សព្វផ្សាយពីការបរិច្ឆេទនៃការរៀបចំវេទិកាដល់ប្រជាពលរដ្ឋទូទៅឱ្យបានដឹង នៅតាមក្តារព័ត៌មានរបស់ខ្លួន
- សំណើ សំណូមពរមួយចំនួនរបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា រដ្ឋបាលក្រុង ស្រុក ខណ្ឌ មិនអាចដោះស្រាយបាន ដោយសារបញ្ហាទាំងនោះមានការពាក់ព័ន្ធជាមួយស្ថាប័នអង្គភាពរបស់រដ្ឋនៅថ្នាក់លើ



*ប្រជាពលរដ្ឋចូលរួមលើកឡើងនូវសំណួរ សំណូមពរ និងបញ្ហានានាក្នុងវេទិកា*

- សំណួរបញ្ហាលំបាកមួយចំនួនដែលប្រជាពលរដ្ឋលើកឡើង ហើយពុំទាន់បានផ្តល់ដំណោះស្រាយឬមិនទាន់បានឆ្លើយបំភ្លឺគឺប្រធានក្រុមប្រឹក្សាអភិបាល ឬអ្នកពាក់ព័ន្ធ មិនប្រាប់ប្រជាពលរដ្ឋពីវិធានការដោះស្រាយបន្ត ឬពេលវេលាដែលត្រូវផ្តល់ព័ត៌មានទៅប្រជាពលរដ្ឋវិញ
- ក្រុង ស្រុកមួយចំនួនបានបញ្ចប់វេទិការបស់ខ្លួនឆាប់ពេកជាហេតុធ្វើឱ្យអ្នកចូលរួមមិនបានបញ្ចេញមតិ ឬបានលើកយោបល់ជូនវេទិកា
- ទីកន្លែងសម្រាប់រៀបចំវេទិកាមិនទាន់ល្អព្រោះភាគច្រើនធ្វើនៅក្នុងបរិវេណសាលាក្រុងស្រុកដែលមានទីកន្លែងតូចចង្អៀត ដែលមិនអាចឱ្យប្រជាពលរដ្ឋចូលរួមបានច្រើន។ ម្យ៉ាងទៀត ការរៀបចំវេទិកានៅសាលាក្រុង ស្រុក ខណ្ឌគឺប្រជាពលរដ្ឋពុំសូវហ៊ានបញ្ចេញមតិត្រង់ៗចំពោះការខ្វះខាតលើការបំពេញការងាររបស់ស្ថាប័ន អង្គភាពពាក់ព័ន្ធ
- ក្រុមប្រឹក្សាមិនទាន់បានដាក់បញ្ហាដែលលើកឡើងដោយប្រជាពលរដ្ឋទៅក្នុងសកម្មភាពអាទិភាពរបស់រដ្ឋបាលក្រុង ស្រុកខណ្ឌសម្រាប់សកម្មភាពអាទិភាពឆ្នាំ២០១៤នៅឡើយ។

## V. សំណើ/បញ្ហានានាលើកឡើងដោយអ្នកចូលរួម

ក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ប្រជាពលរដ្ឋសំណូមពរ ដូចខាងក្រោម៖

- ស្នើក្រុង ស្រុក ជួយដោះស្រាយបញ្ហាទំនាស់ដីធ្លីជាមួយបណ្តាក្រុមហ៊ុនដីសម្បទាន
- ក្រុង ស្រុកមេត្តាពិភាក្សា សម្របសម្រួលជាមួយក្រុមហ៊ុនបញ្ចុះតម្លៃភ្លើងអគ្គីសនី និងទឹក
- សូមរាជរដ្ឋាភិបាល និងអាជ្ញាធរគ្រប់ថ្នាក់ ស្វែងរកទីផ្សារសម្រាប់ផលដំណាំ ព្រោះដំណាំផលិតបាន មានតម្លៃទាបពេក
- សូមរដ្ឋបាលក្រុង ស្រុក ជំរុញការិយាល័យអប់រំក្រុង ស្រុកជួយអន្តរាគមន៍ដល់គ្រូបង្រៀនមួយចំនួននៅតាមសាលារៀនមួយចំនួន ឱ្យគោរពពេលម៉ោង និងទៅបង្រៀនបានជាប់លាប់
- សូមរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ជួយសម្របសម្រួលបញ្ចុះតម្លៃសេវានៅមណ្ឌលសុខភាព
- សូមអាជ្ញាធរមានសមត្ថកិច្ចកុំយកតម្លៃថ្លៃពេកក្នុងការធ្វើសៀវភៅស្នាក់នៅ
- សូមសមត្ថកិច្ចពាក់ព័ន្ធជួយកាត់បន្ថយអំពើហឹង្សាក្នុងគ្រួសារ ដូចជាការរំលោភបំពានលើស្រ្តី
- ស្នើឱ្យឃុំប្រាប់ពីតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ និងសំណូមពរឱ្យក្រុមប្រឹក្សាឃុំ ប្រជុំប្រាប់ប្រជាជនពីគម្រោងអ្វីមួយដែលឃុំត្រូវធ្វើ



***តំណាងអង្គការសង្គមស៊ីវិលចូលរួមលើកឡើងនូវសំណួរ សំណូមពរ និងបញ្ហានានាក្នុងវេទិកា***

- ស្នើរដ្ឋបាលស្រុក ណែនាំដល់ប៉ុស្តិ៍រដ្ឋបាលព្រៃឈើនិងបរិស្ថាននៅតាមដងផ្លូវ កុំឱ្យយកលុយពីប្រជាពលរដ្ឋដែលដឹកជញ្ជូនអនុផលព្រៃឈើ

- ស្នើរដ្ឋបាលក្រុង ស្រុកជួយប្រាប់ប្រជាពលរដ្ឋផង តើការស្នើសុំច្បាប់ដឹកឈើមកសង់ផ្ទះប្រជាពលរដ្ឋត្រូវទៅសុំការអនុញ្ញាតពីសមត្ថកិច្ចណាមួយ
- ស្នើឱ្យស្រុក ពិភាក្សា និងប្រមូលពីតម្រូវការរបស់ប្រជាពលរដ្ឋ នៅពេលធ្វើគម្រោងអភិវឌ្ឍផ្សេងៗ
- ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋនៅមិនទាន់បានល្អប្រសើរ និងទាន់ពេលវេលា
- សំណូមពរគ្រូក្របខ័ណ្ឌបន្ថែម និងជួយចាត់វិធានដោះស្រាយការបោះបង់ការសិក្សារបស់សិស្ស
- សំណូមពរ ជំរុញការផ្តល់សេវាសុខភាព និងការពង្រឹងមណ្ឌលសុខភាព
- រាល់ការប្រជុំរបស់ក្រុមប្រឹក្សាគួតែអញ្ជើញប្រជាជននិងសង្គមស៊ីវិលឱ្យចូលរួមផង
- ក្រុមប្រឹក្សាគួរធ្វើវេទិកាបែបនេះជាប្រចាំត្រីមាស
- ក្រុមប្រឹក្សាគួធ្វើផែនការឱ្យបានជាក់លាក់ក្នុងការចុះជួបសំណេះសំណាលស្តាប់ពីតម្រូវការ និងបញ្ហារបស់ប្រជាពលរដ្ឋ
- ក្រុមប្រឹក្សាគួរមានវិធីសាស្ត្រងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទំនាក់ទំនងនិងទទួលយកព័ត៌មានត្រឡប់ព្រមទាំងការឆ្លើយតប។

## VI. សកម្មភាពអាទិភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងឆ្នាំ២០១៤

ជារួម តាមការពិនិត្យលើផែនការសកម្មភាពអាទិភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌសម្រាប់ឆ្នាំ២០១៤មានដូចខាងក្រោមៈ

- ប្រជុំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋលើច្បាប់ចរាចរច្បាប់គ្រឿងញៀន ច្បាប់បង្ក្រាបក្មេងទំនើងពិសេសផ្សព្វផ្សាយផែនការលេខ០២២របស់ក្រសួងមហាផ្ទៃស្តីពីភូមិ ឃុំមានសុវត្ថិភាព
- លើកកម្ពស់ការផ្តល់សេវាសុខភាពប្រជាពលរដ្ឋ ពិសេសកាត់បន្ថយអត្រាមរណភាពមាតា និងទារក
- ជំរុញការចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណប័ណ្ណ
- ទប់ស្កាត់និងបង្ក្រាបបទល្មើសគ្រប់ប្រភេទពិសេសការកាប់ព្រៃឈើការរានព្រៃយកដីធ្វើជាកម្មសិទ្ធិនិងការនេសាទខុសច្បាប់
- ជំរុញការផ្សព្វផ្សាយទប់ស្កាត់ការធ្វើចំណាកស្រុកទៅរកការងារធ្វើនៅខាងក្រៅប្រទេស
- រៀបចំកម្មវិធីវិនិយោគ៣ឆ្នាំរំកិលប្រចាំឆ្នាំរបស់ ក្រុង ស្រុក
- សហការ និងសម្របសម្រួលការអនុវត្តគម្រោងរបស់អង្គការនានាដែលមានសកម្មភាពក្នុងក្រុង ស្រុក
- ធ្វើសៀវភៅគ្រួសារក២ក៤និងឯកសារផ្សេងៗតាមតម្រូវការរបស់ប្រជាពលរដ្ឋ
- ពង្រឹងរបៀបរបបការងារមន្ត្រីរាជការរហូតដល់មូលដ្ឋានតាមខ្លឹមសារណែនាំ និងលិខិតបទដ្ឋានរបស់រាជរដ្ឋាភិបាលពិសេសក្នុងការអនុវត្តកម្មវិធីនយោបាយថ្នាក់ក្រោមជាតិ

- បន្តសម្របសម្រួលនិងជំរុញការដោះស្រាយពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋឱ្យបានល្អប្រសើរ
- ជំរុញមន្ត្រីជំនាញក្នុងការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងការបង្កើនផលិតកម្មដំណាំស្រូវ និងសត្វ ដូចជា៖ ការជ្រើសពូជស្រូវសុទ្ធល្អ មានទិន្នផលខ្ពស់ ការប្រើប្រាស់ជីធម្មជាតិ កាត់បន្ថយជីគីមី បន្តទប់ស្កាត់ការនាំចូលសត្វគ្រប់ប្រភេទពីប្រទេសជិតខាងដែលគ្មានច្បាប់អនុញ្ញាត។ បន្តចាក់វ៉ាក់សាំងការពារជម្ងឺសត្វនៅតាមមូលដ្ឋាននិង ស្រាវជ្រាវកន្លែងមានករណីផ្ទុះនូវជម្ងឺសត្វ និងបន្តអប់រំដល់ភ្នាក់ងារពេទ្យសត្វភូមិ
- ពង្រឹងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយក្នុងក្រុង ស្រុក និងឃុំ សង្កាត់ត្រូវធ្វើផែនការក្នុងការជួយសង្គ្រោះប្រជាពលរដ្ឋដែលជួបការរងគ្រោះមហន្តរាយនិងកំណត់មុខសញ្ញាឱ្យបានច្បាស់ ដើម្បីជួយឱ្យទាន់ពេលវេលា។

## VII. សន្និដ្ឋានលើដំណើរការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់

ឆ្លងតាមការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ រដ្ឋបាលក្រុង ស្រុក ខណ្ឌ បានធ្វើបូកសរុប និងសន្និដ្ឋានដូចខាងក្រោម៖

- ការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌពិតជាបានផ្តល់ឱកាសដល់ ប្រជាពលរដ្ឋ តំណាងសង្គមស៊ីវិល បានលើកឡើងពីកង្វល់ បញ្ហា សំណូមពរនានាដែលកើតឡើងជាក់ស្តែងនៅមូលដ្ឋាន ហើយវេទិកានេះ គឺជាយន្តការល្អប្រសើរមួយក្នុងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ និងការទទួលខុសត្រូវរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ



*តំណាងក្រុមយុវជនចូលរួមក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នៅស្រុក ស្នួលខេត្តក្រចេះ*

- ការរៀបចំវេទិការបស់ក្រុមប្រឹក្សាក្រុងស្រុក ខណ្ឌ នាពេលនេះក៏ជាមេរៀនបទពិសោធន៍ដ៏សំខាន់សម្រាប់រដ្ឋបាលក្រុងស្រុក ខណ្ឌ ឱ្យមានទំនុកចិត្តលើការបំពេញការងាររបស់ខ្លួន។ ម្យ៉ាងទៀត ការចូលរួមមតិយោបល់ និងការរិះគន់ក្នុងន័យស្ថាបនារបស់ប្រជាពលរដ្ឋនៅក្នុងវេទិកាបានធ្វើឱ្យរដ្ឋបាលក្រុងស្រុក ខណ្ឌ បានផ្តល់នូវតម្លៃទៅលើមតិយោបល់របស់ប្រជាពលរដ្ឋដើម្បីកែលម្អការផ្តល់សេវាសាធារណៈផងដែរ
- ទោះបីការរៀបចំវេទិកាជាជំហានដំបូងសម្រាប់អាណត្តិក្រុមប្រឹក្សាក៏ដោយក៏ដំណើរការប្រព្រឹត្តទៅបានល្អប្រសើរដោយមានការប្រឹក្សាយោបល់ពីមន្ត្រីសម្របសម្រួលក្រុមប្រឹក្សា ខេត្ត ក្រុង ស្រុក ខណ្ឌ និងមានការសហការពីទីប្រឹក្សាកម្មវិធីជាតិថ្នាក់ក្រុង ស្រុក និងការចូលរួមពីនាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ក្នុងនោះការយកចិត្តទុកដាក់ពីគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌអំពីនីតិវិធី និងរបៀបរៀបចំវេទិកា
- វេទិកានេះបានផ្តល់ឱ្យអ្នកចូលរួមបានយល់ដឹងពីលទ្ធផលជាក់ស្តែងនៅមូលដ្ឋានកាន់តែច្បាស់ពីការបំពេញតួនាទីភារកិច្ចរបស់គណៈអភិបាល ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- ចំពោះសំណួរនិងសំណូមពរភាគច្រើន ដែលលើកឡើងដោយប្រជាពលរដ្ឋ ត្រូវបានបកស្រាយ និងឆ្លើយបំភ្លឺពីមន្ត្រីជំនាញតាមមន្ទីរ ឬការិយាល័យជំនាញ ព្រមទាំងក្រុមប្រឹក្សា និងលោកអភិបាលក្រុង ស្រុក ខណ្ឌ ផងដែរ ទោះបីចម្លើយ ឬការបកស្រាយទាំងនោះពុំទាន់ទទួលយកបាន ទាំងស្រុងពីប្រជាពលរដ្ឋក៏ដោយ




*ប្រធានក្រុមប្រឹក្សា អភិបាល និងតំណាងការិយាល័យជំនាញជុំវិញស្រុក*

- រដ្ឋបាលក្រុង ស្រុក ខណ្ឌ ភាគច្រើនបានរៀបចំការវាយតម្លៃលើសំណើ សង្ខេបលទ្ធផលនិងឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋក្នុងវេទិកាដើម្បីដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាពិភាក្សា និងរិះរកវិធានការដោះស្រាយនូវបញ្ហាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុង ស្រុក ខណ្ឌ បានបញ្ចូលបញ្ហា វិធានការដោះស្រាយមួយចំនួនទៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ប្រចាំត្រីមាសរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលត្រូវអនុវត្តដោយគណៈអភិបាល និងមានការតាមដាន ត្រួតពិនិត្យដោយក្រុមប្រឹក្សាក្រុង ស្រុកខណ្ឌតាមរយៈរបាការណ៍រីកចម្រើនក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដូចជាបញ្ហាកម្រៃសេវាធ្វើលិខិតអត្រានុកូលដ្ឋាន បញ្ហាកុងត្រូលជជុះ ល្បែងស៊ីសងក្នុង មូលដ្ឋាន តម្លៃភ្លើងអគ្គីសនី។ល។



***តំណាងការិយាល័យភូមិបាលស្រុកឆ្លើយបំភ្លឺសំណួរដែលលើកឡើងដោយប្រជាពលរដ្ឋ ក្នុងវេទិកាស្រុកសៀមបូក ខេត្តស្ទឹងត្រែង***

- អ្នកចូលរួមទាំងអស់បានដឹងអំពីតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុកលទ្ធផលការងារដែលក្រុមប្រឹក្សាក្រុង ស្រុកសម្រេចបាន ការគ្រប់គ្រងថវិកា ផែនការសកម្មភាពការងាររបស់ក្រុមប្រឹក្សាក្រុង ស្រុកសម្រាប់ឆ្នាំបន្ទាប់ និងការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ក្នុងនោះដែរ ដោយសារការរៀបចំវេទិកាជាលើកដំបូង គឺនៅមានការខ្វះចន្លោះដែរ ដូចជា ការអញ្ជើញអ្នកពាក់ព័ន្ធមិនទាន់បានទូលំទូលាយ ខ្វះឯកសារសម្រាប់អ្នកចូលរួមប្រជាពលរដ្ឋដែល

មិនបានអញ្ជើញពុំហ៊ានចូលរួម

- បញ្ហាមួយចំនួនដែលប្រជាពលរដ្ឋស្នើសុំឱ្យក្រុង ស្រុក ខណ្ឌជួយដោះស្រាយ គឺហួសពីសមត្ថកិច្ច របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ហើយអង្គភាពពាក់ព័ន្ធទាំងនោះពុំមានការិយាល័យ ឬស្នាក់ការធ្វើ ការនៅក្នុងក្រុង ស្រុក ខណ្ឌទៀតផង ដែលធ្វើឱ្យមានការលំបាកសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការ ទំនាក់ទំនងផ្សេងៗ
- សំណើ សំណូមពររបស់ប្រជាពលរដ្ឋដើម្បីឱ្យរដ្ឋបាលក្រុង ស្រុក ដោះស្រាយមានទំហំធំៗ ហើយច្រើនពេក ដែលក្រុង ស្រុក ពុំមានថវិកាគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហា សំណូមពររបស់ប្រជាពលរដ្ឋដែលផ្នែកហេដ្ឋារចនាសម្ពន្ធ័ មានលក្ខណៈទ្រង់ទ្រាយធំ និងលក្ខណៈជំនាញបច្ចេកទេស។

## VIII. អនុសាសន៍កែលម្អសម្រាប់រៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ឆ្នាំបន្ទាប់

យោងតាមបទពិសោធន៍នៃការគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងការពិភាក្សាផ្ទាល់ជាមួយក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ក្នុងការរៀបចំវេទិកាផ្សព្វផ្សាយនិង ពិគ្រោះយោបល់ ក្រុមការងារនៃអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយរបស់លេខាធិការដ្ឋានគ.ជ.អ.ប សូមលើកនូវអនុសាសន៍ និងសំណូមពរមួយចំនួនរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីកែលម្អនូវការរៀបចំវេទិការនៅបណ្តាឆ្នាំខាងមុខ ដូចខាងក្រោម៖

- ស្ថាប័ន អង្គភាពពាក់ព័ន្ធ នៅថ្នាក់ខេត្ត (សាលាខេត្ត មន្ទីរហិរញ្ញវត្ថុ និងរតនាគារខេត្ត) ត្រូវគាំទ្រដល់រដ្ឋបាលក្រុង ស្រុកដែលបានគ្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួនសម្រាប់រៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ ព្រោះកិច្ចការនេះជាមុខងារជាកាតព្វកិច្ចដែលក្រុមប្រឹក្សាក្រុង ស្រុក ត្រូវរៀបចំធ្វើប្រចាំឆ្នាំ។ ការលើកឡើងដូច្នេះ ដោយសារកន្លងមក ទោះបីរដ្ឋបាលក្រុងស្រុកបានលើកផែនការសកម្មភាពនៃការរៀបចំវេទិកាបញ្ចូលក្នុងផែនការថវិកាប្រចាំឆ្នាំរបស់ខ្លួន(ដោយបញ្ចូលក្នុងខ្ទង់ថវិកាផ្នែកប្រតិបត្តិការ) ប៉ុន្តែដំណើរការចំណាយជាក់ស្តែង មានការលំបាកក្នុងការលៃលកដើម្បីប្រើប្រាស់ថវិកានេះ។ ចំពោះរដ្ឋបាលរាជធានី ពុំមានបញ្ហាខ្វះថវិកាសម្រាប់ខណ្ឌនានាក្នុងការចំណាយលើការរៀបចំ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ នោះទេ
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបិទផ្សាយឱ្យបានទូលំទូលាយ គ្រប់មធ្យោបាយនូវកាលបរិច្ឆេទ ទីកន្លែង ប្រធានបទសំខាន់ៗនៃការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ដល់ប្រជាពលរដ្ឋតាមក្តារព័ត៌មានរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្តារព័ត៌មានឃុំ សង្កាត់ និងតាមភូមិនានា ដើម្បីឱ្យប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាអាចចូលរួមបានដោយពុំចាំបាច់មានការអញ្ជើញ

- រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ពេលវេលាឱ្យបានច្បាស់លាស់ក្នុងការឆ្លើយតបចំពោះសំណើ សំណូមពរទាំងឡាយដែលបានលើកឡើងដោយអ្នកចូលរួមក្នុងវេទិកា។
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការផ្សព្វផ្សាយខ្លឹមសារសង្ខេបសំខាន់ៗអំពីលទ្ធផលរបស់វេទិកាតាមមធ្យោបាយផ្សេងៗឱ្យដល់ប្រជាពលរដ្ឋ
- រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវជំរុញការិយាល័យជំនាញអង្គការសង្គមស៊ីវិលនិងក្រុមហ៊ុនឯកជនពិសេសក្រុមហ៊ុនដែលកំពុងធ្វើអាជីវកម្មផ្ទាល់ជាមួយប្រជាពលរដ្ឋដែរនោះដូចជា៖ ក្រុមហ៊ុនទឹកស្អាតក្រុមហ៊ុនអគ្គីសនីក្រុមហ៊ុនប្រមូលសំរាមជាដើមត្រូវចូលរួមពន្យល់បកស្រាយបំភ្លឺ ចំពោះសំណួរ ឬបញ្ហានានាដែលលើកឡើងដោយប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងជីវភាពរស់នៅរបស់ពួកគាត់
- បន្ទាប់ពីបញ្ចប់វេទិកា ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវមានភារកិច្ចផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានានូវលទ្ធផល ដូចជាសមិទ្ធិផលដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌសម្រេចបាន បញ្ហា និងសំណូមពរនានាដែលលើកឡើងដោយអ្នកចូលរួម និងដំណោះស្រាយនានាដែលក្រុមប្រឹក្សា និងអ្នកពាក់ព័ន្ធបានឆ្លើយបំភ្លឺ
- បញ្ហាមួយចំនួនដែលបានលើកឡើងក្នុងវេទិកា ហើយពុំទាន់អាចដោះស្រាយ រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវយកបញ្ហាទាំងនោះមកប្រជុំពិភាក្សាជាមួយអង្គភាព ស្ថាប័ន និងការិយាល័យជំនាញពាក់ព័ន្ធ ដើម្បី រិះរកវិធានការ និងមធ្យោបាយដោះស្រាយ កំណត់ពេលវេលាដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋវិញ។ ការផ្សព្វផ្សាយ ឬផ្ដល់ព័ត៌មានអាចធ្វើតាមរយៈក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានមកចូលរួមប្រជុំក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងបិទផ្សាយតាមក្ដារព័ត៌មាន។ ចំពោះបញ្ហា ឬសំណូមពរដែលពុំទាន់អាចដោះស្រាយបានដោយសារពាក់ព័ន្ធជាមួយស្ថាប័នអង្គភាពជំនាញនៅថ្នាក់លើ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនបញ្ហាទាំងនេះមកថ្នាក់លើបន្តទៀត ព្រមទាំងចាត់តាំងមន្ត្រីក្នុងការតាមដានលទ្ធផលនៃកិច្ចការទាំងនោះ ហើយត្រូវរាយការណ៍ជូនក្រុមប្រឹក្សា។